# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា
## កិច្ចព្រមព្រៀងរវាង សាលា និង មាតាបិតា

*<u>វិទ្យាល័យ ហ្វើនេស្ស (FURNESS)</u> និង មាតាបិតារបស់សិស្សានុសិស្សដែលចូលរួមក្នុង សកម្មភាព ការបម្រើ និង កម្មវិធី ដែលឧបត្ថម្ភដោយច្បាប់ Title I, Part A នៃច្បាប់ សាលាបឋមសិក្សា និង វិទ្យាល័យ (Elementary and Secondary Education Act, ESEA) យល់ព្រមថាកិច្ចព្រមព្រៀងនេះ រៀបរាប់ដោយសង្ខេបអំពីវិធីដែល មាតាបិតា បុគ្គលិករបស់សាលាទាំងអស់ និង សិស្សានុសិស្ស នឹងមានការទទួលខុសត្រូវរួមគ្នា ដើម្បីបង្កើន ជោគជ័យនៃ ការសិក្សារបស់សិស្ស និង វិធីដែល មាតាបិតា និង សាលា នឹងបង្កើត និង អភិវឌ្ឍ ជាដៃគូរ ដែលអាចជួយក្មេងឲ្យសម្រេចបានតាម ខ្នាតគំរូកម្រិត ខ្ពស់របស់រដ្ឋ។*

*កិច្ចព្រមព្រៀងរវាង សាលា និង មាតាបិតា នេះ មានប្រសិទ្ធិភាពសម្រាប់ឆ្នាំសិក្សា* **២០១៥-២០១៦** ។

## <u>ការផ្តល់ជូននូវតម្រូវការសង្ខេបនៃកិច្ចព្រមព្រៀងរវាង សាលា និង មាតាបិតា</u>

### <u>ការទទួលខុសត្រូវរបស់សាលា</u>

**<u>វិទ្យាល័យ ហ្វើនេស្ស</u> នឹង៖**

**១. ផ្តល់កម្មវិធីសិក្សា និង ការបង្ហាត់បង្រៀន ដែលមានគុណភាពខ្ពស់ ក្នុងបរិយាកាសសិក្សាដែលមានការគាំទ្រ និងមានប្រសិទ្ធិភាព ដែលអាចឲ្យសិស្សដែលចូលរួម ធ្វើបានតាមខ្នាតគំរូនៃការសិក្សារបស់សិស្ស របស់រដ្ឋ ដូចតទៅ៖**

- *ធ្វើតាម និង អនុវត្ត កម្មវិធីសិក្សាសំខាន់ៗ តាមការតម្រូវរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា*
- *អនុវត្តតាមគម្រោងការដ៏ទូលំទូលាយរបស់ វិទ្យាល័យ ហ្វើនេស្ស*
- *ការបង្កើតសហគមន៍អ្នកជំនាញសម្រាប់គ្រូ*
- *រៀបចំ/កំណត់ពេល ប្រជុំប្រចាំខែ សម្រាប់សហគមន៍អ្នកជំនាញ*
- *ផ្តល់ការហ្វឹកហ្វឺនផ្នែកវិជ្ជាជីវៈនៅក្នុងសាលា*

**២. រៀបចំឲ្យមានអង្គប្រជុំរវាង មាតាបិតា និង គ្រូ (យ៉ាងហោចណាស់មួយឆ្នាំម្តង នៅសាលាបឋមសិក្សា) នៅពេលនោះគេនឹងពិភាក្សាអំពីកិច្ចព្រមព្រៀងនេះ តាមការដែលមានការទាក់ទងជាមួយនឹងជោគជ័យរបស់ក្មេងម្នាក់ៗ។ ជាពិសេស អង្គប្រជុំទាំងនោះនឹងប្រព្រឹត្តទៅនៅ៖**

- *យប់ជួបប្រជុំជាមួយបុគ្គលិកសាលាដំបូង ថ្ងៃទី៣០ ខែកញ្ញា ២០១៥/*Back to School Night on September 30, 2015
- *ថ្ងៃពិពណ៌មហាវិទ្យាល័យ - នឹងប្រកាសនៅថ្ងៃក្រោយ/*College Fair Day – TBD
- *ពិពណ៌វប្បធម៌ចម្រុះប្រចាំឆ្នាំ - នឹងប្រកាសនៅថ្ងៃក្រោយ/*Annual Multicultural Fair – TBD
- *ជួបប្រជុំជាមួយ សិស្ស/គ្រូ/មាតាបិតា ម្នាក់ៗ ទៅតាមសេចក្តីត្រូវការ/*Individual Student/Teacher/Parent meetings as needed
- *អង្គប្រជុំចែករបាយការណ៍ពិន្ទុ -/*Report Card Conferences –
    i. *ថ្ងៃទី២ ដល់ ទី៤ ខែធ្នូ ឆ្នាំ២០១៥/*December 2 – 4, 2015
    ii. *ថ្ងៃទី២៣ ដល់ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥/*February 23 – 25, 2015
    iii. *ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥/*April 27, 2015

៣. **ផ្តល់របាយការណ៍ជូនមាតាបិតាឲ្យបានញឹកញាប់ អំពីការរីកចម្រើនរបស់កូនគាត់។**
ជាពិសេស សាលានឹងផ្តល់របាយការណ៍ដូចតទៅ៖

- *របាយការណ៍ពិន្ទុបណ្តោះអាសន្ន រៀងរាល់ត្រីមាស/*Interim report for every marking period
- *អង្គប្រជុំ* IEP *សម្រាប់សិស្សដែលមាន* IEP/IEP Meetings for students with IEP

៤. **អនុញ្ញាតឲ្យមាតាបិតាជួបជាមួយបុគ្គលិក តាមលក្ខណៈសមហេតុផល។** ជាពិសេស បុគ្គលិកអាចមានពេលដើម្បីពិភាក្សាជាមួយមាតាបិតា ដូចតទៅ៖

- *យប់ជួបប្រជុំជាមួយបុគ្គលិកសាលា ដំបូង/*Back to School Night
- *ការណែនាំសិស្សវិទ្យាល័យឆ្នាំទី១/*Freshmen Orientation
- *យប់ស្វែងយល់ពីមហាវិទ្យាល័យ/*College Night
- *ពិពណ៌វប្បធម៌ចម្រុះ/*Multicultural Fair
- *ដំណើរកម្សាន្តសម្រាប់ការសិក្សា/* Class Trips
- *អង្គប្រជុំសមាគម មាតាបិតា និង សាលា/*Home and School Association Meetings
- *ការបម្រើផ្នែក* RtII/RtII Services
- *អង្គប្រជុំ* IEP/ IEP Meetings
- *ពិធីចែករង្វាន់/*Award Ceremonies
- *ការជួបជុំសម្រាប់សិស្សដែលមានវត្តមានជារៀងរាល់ថ្ងៃ/*Perfect Attendance Assemblies
- *អង្គប្រជុំនៅពេលមាតាបិតាស្នើសុំ/*Meetings per parents' requests
- *អង្គប្រជុំ តាមការណាត់ជួប និង ជាមួយ រដ្ឋបាល/គ្រូ/*By appointment and administrators/teacher conference

៥. **ផ្តល់ឱកាសឲ្យមាតាបិតាអាច ស្ម័គ្រចិត្ត និង ចូលរួម ក្នុងថ្នាក់រៀនរបស់កូន និងអាចសង្កេតមើលសកម្មភាពនៅក្នុងថ្នាក់រៀន** ដូចតទៅ៖

- *អ្នកជំនួយការនៅការិយាល័យ/ Clerical Assistant*
- *អ្នកត្រួតពិនិត្យនៅតាមអាគារ/Hall monitor*
- *រៀបចំ និង ចូលរួមក្នុងការជួបជុំគ្នា/ Organize and participate in assemblies*
- *ជួយមើលខុសត្រូវក្មេងនៅពេលធ្វើដំណើរកម្សាន្តសិក្សា / Chaperon for trips*

<u>**ការទទួលខុសត្រូវរបស់មាតាបិតា**</u>

**ក្នុងនាមជាមាតាបិតា យើងខ្ញុំនឹងជួយដល់ការសិក្សារបស់កូន តាមវិធីដូចតទៅ៖**

*[រៀបរាប់ពីវិធីដែលមាតាបិតានឹងជួយដល់ការសិក្សារបស់កូន ដូចជា៖*

- *តាមដាន វត្តមានអវត្តមាន។*
- *ធ្វើយ៉ាងណាឲ្យកូនធ្វើកិច្ចការដែលគ្រូឲ្យយកមកធ្វើនៅផ្ទះ ឲ្យបានចប់សព្វគ្រប់។*
- *គ្រប់គ្រងពេលវេលាដែលកូនខ្ញុំមើលទូរទស្សន៍។*
- *ស្ម័គ្រចិត្តជួយនៅក្នុងថ្នាក់រៀនរបស់កូនខ្ញុំ។*
- *ចូលរួមក្នុងការសម្រេចដែលទាក់ទងនឹងការអប់រំរបស់កូនខ្ញុំ តាមលក្ខណៈសមរម្យ។*
- *ជំរុញចំណុចវិជ្ជមាន ក្នុងការប្រើពេលវេលាក្រៅកម្មវិធីសិក្សារបស់កូនខ្ញុំ។*

- *តាមដានឲ្យដឹងអំពីការអប់រំរបស់កូនខ្ញុំ ហើយទាក់ទងជាមួយសាលា តាមរយៈការអានលិខិតទាំងអស់ដែលមកពី សាលា ឬ ក្រសួងអប់រំ ដែលផ្ញើមកតាមកូនខ្ញុំ ឬ តាមប៉ុស្តិ៍សំបុត្រ ជាបន្ទាន់ ហើយឆ្លើយតបទៅវិញតាមលក្ខណៈសមរម្យ។*
- *តាមតែអាចធ្វើទៅបាន ចូលបម្រើក្នុង ក្រុមប្រឹក្សាច្បាប់ ដូចជា អ្នកតំណាងឲ្យមាតាបិតាផ្នែកច្បាប់ Title I, Part A ក្នុងក្រុមកែលម្អសាលា របស់សាលា គណកម្មាធិការក្រុមប្រឹក្សាច្បាប់ Title I ក្រុមប្រឹក្សាច្បាប់ទូទាំងក្រសួង គណកម្មាធិការផ្នែកអ្នកអនុវត្ត របស់រដ្ឋ ក្រុមអ្នកគាំទ្រសាលា ឬ ក្រុមប្រឹក្សាសាលា ឬ ក្រុមប្រឹក្សាច្បាប់ ផ្សេងៗទៀត។]*

៙៚

***<u>ការទទួលខុសត្រូវរបស់សិស្ស (កែសម្រួលឲ្យសមស្របទៅតាមកម្រិតថ្នាក់)</u>***

ក្នុងនាមជាសិស្ស យើងខ្ញុំនឹងចូលរួមក្នុងការទទួលខុសត្រូវដើម្បីបង្កើនជោគជ័យនៃការសិក្សារបស់យើងខ្ញុំ និង ធ្វើឲ្យបានសម្រេចតាមខ្នាតគំរូ កម្រិតខ្ពស់របស់រដ្ឋ។ ជាពិសេស យើងខ្ញុំនឹង៖

***[រៀបរាប់ពីវិធីដែលសិស្សនឹងជួយដល់ជោគជ័យក្នុងការសិក្សារបស់ខ្លួន ដូចជា៖***

- ***ធ្វើកិច្ចការដែលគ្រូឲ្យយកមកធ្វើនៅផ្ទះជារៀងរាល់ថ្ងៃ ហើយសុំជំនួយនៅពេលដែលខ្ញុំត្រូវការ។***
- ***អាននៅក្រៅម៉ោងសិក្សា យ៉ាងហោចណាស់៣០នាទី ជារៀងរាល់ថ្ងៃ។***
- ***ប្រគល់ជូនមាតាបិតា ឬ មនុស្សពេញវ័យ ដែលទទួលខុសត្រូវលើខ្លួនខ្ញុំ នូវលិខិត និង ព័ត៌មាន ទាំងអស់ ដែលសាលាបានឲ្យមកខ្ញុំ ជារៀងរាល់ថ្ងៃ។]***

**<u>វិទ្យាល័យ</u>** <u>ហ្វើនេស្ស</u> នឹង៖ (ត្រូវមាននៅក្នុងកិច្ចព្រមព្រៀងទាំងអស់)

១. ឲ្យមាតាបិតាចូលរួមក្នុងការ រៀបចំ ពិនិត្យមើលឡើងវិញ និង កែលម្អ ច្បាប់នៃការចូលរួមរបស់មាតាបិតា តាមការ ចាត់ចែង ធ្វើជាបន្ត និង ទាន់ពេលវេលា។

២. ឲ្យមាតាបិតា ចូលរួមក្នុងការបង្កើតរួមគ្នា អំពីផែនការនៃកម្មវិធីទូទាំងសាលាទាំងអស់ តាមការ ចាត់ចែង ធ្វើជាបន្ត និង ទាន់ពេលវេលា។

៣. រៀបចំអង្គប្រជុំប្រចាំឆ្នាំ ដើម្បីជូនដំណឹងដល់មាតាបិតារបស់សាលា ដែលចូលរួមក្នុងកម្មវិធីរបស់ច្បាប់ **Title I, Part A** និង ពន្យល់ពីការតម្រូវនៃច្បាប់ **Title I, Part A** និងសិទ្ធិដែលមាតាបិតាអាចចូលរួមក្នុងកម្មវិធីរបស់ច្បាប **Title I, Part A** ។ សាលានឹងរៀបចំអង្គប្រជុំនៅម៉ោងដែលងាយស្រួលសម្រាប់មាតាបិតា ហើយនឹងផ្តល់អង្គប្រជុំអំពីការចូលរួមរបស់មាតាបិតា នៅម៉ោងខុសៗគ្នាបន្ថែមទៀត ដូចជា នៅពេលព្រឹក ឬ នៅពេលយប់ ដើម្បីអាចឲ្យមាតាបិតាចូលរួមឲ្យបានច្រើន។ សាលានឹងអញ្ជើញមាតាបិតារបស់សិស្សដែលចូលរួមក្នុងកម្មវិធីរបស់ច្បាប់ **Title I, Part A** (សិស្សានុសិស្សដែលចូលរួម) ទាំងអស់ឲ្យមកចូលរួមក្នុងអង្គប្រជុំនេះ ហើយនឹងជំរុញឲ្យគាត់មកចូលរួម។

៤. ផ្តល់ព័ត៌មានជូនមាតាបិតារបស់សិស្សដែលចូលរួម តាមវិធីដែលអាចយល់បាន និង ទម្រង់តែមួយដូចគ្នា ព្រមទាំងតាមទម្រង់ផ្សេងទៀត តាមការស្នើសុំរបស់មាតាបិតាដែលពិការ ជាភាសាដែលមាតាបិតាអាចយល់ តាមការដែលអាចធ្វើទៅបាន។

៥. ផ្តល់ព័ត៌មានជូនមាតាបិតារបស់សិស្សដែលចូលរួមឲ្យទាន់ពេលវេលា អំពីកម្មវិធីរបស់ច្បាប់ **Title I, Part A** ដែលរួមទាំង ការរៀបរាប់ និង ការពន្យល់ អំពីកម្មវិធីសិក្សារបស់សាលា វិធីនៃការវាយតម្លៃការសិក្សាដែលប្រើដើម្បីវាស់មើលការរីកចម្រើនរបស់ក្មេង និង កម្រិតនៃចំណេះដឹងរបស់សិស្ស ដែលគេចង់បាន។

៦. តាមសំណើរបស់មាតាបិតា ផ្តល់ឱកាសឲ្យមានការជួបប្រជុំជាប្រចាំ ដើម្បីឲ្យមាតាបិតាផ្តល់ជាយោបល់ និងចូលរួម តាមលក្ខណៈស័ក្តសម ក្នុងការសម្រេចអំពីការអប់រំរបស់កូនគាត់។ សាលានឹងឆ្លើយតបទៅនឹងយោបល់ទាំងអស់ឲ្យបានឆាប់ តាមការដែលអាចធ្វើទៅបាន។

៧. ផ្តល់ជូនមាតាបិតាម្នាក់ៗ នូវរបាយការណ៍របស់សិស្សម្នាក់ៗ អំពីលទ្ធផលនៃការវាយតម្លៃរបស់រដ្ឋ យ៉ាងហោចណាស់សម្រាប់អំពី គណិតវិទ្យា អក្សរសិល្ប៍ និង ការអាន។

៨. ផ្តល់លិខិតជូនដំណឹងដល់មាតាបិតាម្នាក់ៗឲ្យទាន់ពេលវេលា នៅពេលដែលគេ បានចាត់ ឬ បានបង្រៀន កូនរបស់គាត់ អស់រយៈពេលបួន (៤) សប្តាហ៍ ឬ យូរជាងនេះ ដោយគ្រូដែលមិនសូវមានសមត្ថភាពខ្ពស់ តាមនិយមន័យដែលនៅក្នុងជំពូក ២០០,៥៦ នៃ បទបទបញ្ញាចុងក្រោយបង្អស់របស់ច្បាប់ **Title I ( 67 Fed. Reg. 71710** ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០២)។

ដើម្បីជួយ បង្កើត និង អភិវឌ្ឍ ការសហការជាមួយមាតាបិតា ដើម្បីជួយកូនឲ្យសម្រេចតាមខ្នាតគំរូនៃការសិក្សាកម្រិតខ្ពស់ របស់រដ្ឋ <u>វិទ្យាល័យ ហ្វឺនេស្ស</u> នឹង៖

១. សំណូមពរទៅអ្នកទាក់ទងប្រចាំតំបន់របស់ក្រសួងផ្នែកច្បាប់មិនបន្សល់កុមារ នូវឈ្មោះមាតាបិតារបស់ក្មេងដែលចូលរួមក្នុងកម្មវិធីរបស់ច្បាប់ **Title I, Part A** ដែលមានចំណាប់អារម្មណ៍ក្នុងការបម្រើជា គណកម្មាធិការផ្នែក អនុវត្ត និង ក្រុមគាំទ្រសាលា របស់រដ្ឋ។

២. ជម្រាបជូនមាតាបិតារបស់សាលាដែលចូលរួមក្នុងកម្មវិធី **Early Reading First** កម្មវិធី **Reading First** និង **Even Start Family Literacy** ឲ្យបានដឹងថាកម្មវិធីទាំងនេះមាននៅ ក្នុងសាលា ក្នុងក្រសួង និង ព័ត៌មានសម្រាប់ទាក់ទង។

៣. សហការជាមួយ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ក្នុងការដោះស្រាយបញ្ហា បើសិនជាមាន ក្នុងការអនុវត្តន៍សកម្មភាពសម្រាប់ការចូលរួមរបស់មាតាបិតា ដែលមាននៅក្នុងមាត្រាលេខ ១១១៨ នៃច្បាប់ **Title I, Part A**។

៤. សហការជាមួយ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ដើម្បីធ្វើយ៉ាងណាឲ្យមានច្បាប់ចម្លងនៃ វិធីដាក់ពាក្យបណ្តឹងសម្រាប់ការដោះស្រាយបទល្មើសអ្វីមួយ នៃលក្ខន្តិកៈរបស់រដ្ឋសហព័ន្ធ ឬ បទបញ្ញានៃកម្មវិធីរបស់ច្បាប់ **Title I, Part A** ត្រូវផ្តល់ទៅឲ្យមាតាបិតារបស់សិស្ស និង ភ្នាក់ងារ ឬ អ្នកតំណាង របស់សាលាឯកជន។

| ______________________ | ______________________ | ___________________ |
|---|---|---|
| សាលា | មាតាបិតា | សិស្ស |
| ______________________ | ______________________ | ______________________ |
| ថ្ងៃខែ | ថ្ងៃខែ | ថ្ងៃខែ |

*<u>(មិនតម្រូវឲ្យចុះហត្ថលេខាទេសូមកត់សម្គាល់ថា គេ)</u>*